ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែមេសា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៤ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៥ | ៦ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការគ្រប់គ្រងអាងទន្លេ

កាលពីថ្ងៃទី០៥ និងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងធនធានទឹកនិងឧតុនិយម។



ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំសេចក្តីព្រាងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ ដោយមានគោលបំណងដូចខាងក្រោម៖

ខឿនសេដ្ឋកិច្ចជាតិកម្ពុជាពឹងផ្អែកមួយផ្នែកធំលើវិស័យកសិកម្ម ដែលប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨០% ជាកសិករ។ ផ្អែកលើស្ថានភាពរស់នៅរបស់ប្រជាជន ស្ថានភាពសំបូរបែបនៃធនធានធម្មជាតិ និងស្ថានភាពភូមិសាស្ត្រអំណោយផលគ្រប់វិស័យ គេអាចនិយាយបានថា កម្ពុជាជាប្រទេសកសិកម្ម។ បើនិយាយពីកសិកម្ម គេត្រូវគិតដល់បញ្ហាទឹក ព្រោះថាគេមិនអាចប្រកបរបរកសិកម្មគ្រប់ប្រភេទដោយគ្មានទឹកបានទេ ជាពិសេសសព្វថ្ងៃនេះពិភពលោកកំពុងចាប់អារម្មណ៍ និងយកចិត្តទុកដាក់ពីបញ្ហាទឹក និងគ្រោះមហន្តរាយនានាបង្កឡើងដោយទឹក។ ជាទស្សនវិស័យប្រកបដោយគតិបណ្ឌិត ឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការ ជាក់ស្តែងរបស់ប្រជាកសិករ និងប្រទេសជាតិ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងនូវក្រសួងធនធានទឹកនិងឧតុនិយម ដោយបានចាត់ទុកនូវបេសកកម្មរបស់ក្រសួងនេះ គឺជាការងារអាទិភាពមួយក្នុងជ្រុងទាំងបួននៃមុំចតុកោណរបស់រាជរដ្ឋាភិបាល។ អនុវត្តតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងធនធានទឹក និងឧតុនិយមក្នុងបេសកកម្មរបស់ខ្លួន បានខិតខំបំពេញយ៉ាងសកម្មនូវការងារអាទិភាពចម្បងមួយចំនួនរួមមាន ការងារសាងសង់ ជួសជុល ស្តារឡើងវិញ និងរៀបចំបង្កើតថ្មីហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ



ការងាររៀបចំប្រព័ន្ធត្រួតពិនិត្យទឹកជំនន់ និងអាកាសធាតុ... ក្នុងក្របខ័ណ្ឌទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ច្បាប់គ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាណាចក្រកម្ពុជាបានចូលជាធរមានកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ កន្លងមក និងលិខិតបទដ្ឋានគតិយុត្តនានាក៏ត្រូវបានរៀបចំតាក់តែងឡើងជាបន្តបន្ទាប់។

ទឹក និងធនធានទឹក គឺសំដៅទៅលើហេដ្ឋារចនាសម្ព័ន្ធការងារទឹក និងការវិនិយោគសាធារណៈ ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍនានាបម្រើឲ្យការងារបង្កបង្កើនផលកសិកម្មគ្រប់ប្រភេទទូទាំងប្រទេស។ ម្យ៉ាងទៀត បច្ចុប្បន្ននេះ យើងបានសង្កេតឃើញថា មានភស្តុតាងយ៉ាងច្រើនបានបង្ហាញពីការកើតមានឡើងភាពអនាធិបតេយ្យដែលបង្កើនសម្ពាធមកលើធនធានទឹក ដូចជាការកាប់បំផ្លាញព្រៃឈើនៅតំបន់ទីជម្រាល ការរុករានកាន់កាប់ព្រៃលិចទឹកនៅតំបន់អាងទន្លេនានា ការបង្ហូរទឹកសំណល់ពុលចេញពីទីក្រុងនិងទីប្រជុំជន ការចាក់សំណល់រឹងនិងរាវចូលប្រភពធនធានទឹក ការរំលោភបំពានកាន់កាប់ដីក្នុងអាងទឹក ការចាក់ដីលប់អាងធម្មជាតិ ស្ទឹង ព្រែក បឹងបួ ផ្លូវទឹកនានា និងតំបន់ឆ្នេរជាដើម...។ បាតុភាពអវិជ្ជមានទាំងនេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើប្រភពធនធានទឹកដូចជា ការហូរច្រោះដី ការរេងកករដីនៅបាតទន្លេ ការបាក់ច្រាំងទន្លេ ស្ទឹង ព្រែក ការប្រែប្រួលគុណភាពទឹក ការប្រែប្រួលទ្រង់ទ្រាយទន្លេ ស្ទឹង ព្រែក ការផ្លាស់ប្តូររបបទឹក ទឹកជំនន់ និងការរាំងស្ងួត ព្រមទាំងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។ ឆ្លងកាត់បទពិសោធន៍ប៉ុន្មានឆ្នាំកន្លងមកថ្មីៗនេះ ក្រសួងធនធានទឹក និងឧតុនិយមសម្រេចបានសមិទ្ធផលធំៗជាច្រើនជាបន្តបន្ទាប់ និងអនាគតក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល ដែលមានទិសដៅរួមក្នុងការចូលរួមចំណែកធ្វើឲ្យសម្រេចបាននូវគោលបំណង ០៤យ៉ាងគឺៈ

១.ធានាទឹកគ្រប់គ្រាន់ជូនប្រជាកសិករ សម្រាប់បង្កបង្កើនផលស្រូវឲ្យបាន២ដងក្នុង មួយឆ្នាំលើផ្ទៃដីតែមួយកន្លែង និងកាត់បន្ថយភាពក្រីក្រជាបណ្តើរៗ។

២.ការគ្រប់គ្រង ការប្រើប្រាស់ និងការអភិវឌ្ឍធនធានទឹកឲ្យមានចីរភាព និងប្រសិទ្ធភាព ដើម្បីឲ្យមាននិរន្តរភាពធនធានធម្មជាតិ បរិស្ថាន វប្បធម៌ និងសង្គម។

៣.កែលំអបរិយាកាសនៃអភិបាលកិច្ច តាមរយៈការអភិវឌ្ឍផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព ព្រមទាំងធ្វើឲ្យសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណ និងគោលដៅចម្បងរបស់រាជរដ្ឋាភិបាល។

៤.ជំរុញធនធានទឹកនិងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងទឹក ផ្ទេរការទទួលខុសត្រូវនៃការគ្រប់គ្រងអាងទន្លេដែលថ្នាក់ក្រោមជាតិអាចអនុវត្តបាន បណ្តុះបណ្តាលនូវបច្ចេកវិទ្យាទំនើបនិងថ្មីៗ ដល់មន្ត្រីបច្ចេកទេសថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដ៏ទៃទៀតប្រកបដោយប្រសិទ្ធភាពខ្ពស់[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនសេចក្តីព្រាងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០១៥ នៅវេលាម៉ោង ១៦:០០នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងសមាជិក ECO-SOCC ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ព័ន្ធ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ។

២- សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា (សង្ខេបយោបល់ និងធាតុចូលលើចំណុចសំខាន់ៗ នៃសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ)។

ក្រោយពីបានពិនិត្យ និងពិភាក្សាយ៉ាងផុលផុសមក អង្គប្រជុំបានសម្រេចដូចខាងក្រោម៖



១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ៖ មាត្រា៨

-កថាខណ្ឌទី២ និងទី៤ ដើមកថាខណ្ឌកែឃ្លា **"ដីចំណីមាត់ច្រាំងនិងឆ្នេរ ទៅជា ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រ"**។

-ចំពោះកថាខណ្ឌទី៣(ការកំណត់ដីចំណីមាត់ច្រាំងនិងឆ្នេខាងលើគ្មានអានុភាពប្រតិកម្មចំពោះដីដែលមានបណ្ណកម្មសិទ្ធិរួចហើយមុនពេលអនុក្រឹត្យនេះចូលជាធរមានឡើយ) អង្គប្រជុំបានពិភាក្សាជាច្រើនគួរដកឬទុក បើតាមយោបល់ក្រុមប្រឹក្សាអ្នកច្បាប់ហាក់បីដូចជាមិនចង់ដាក់ទេព្រោះខុសនិងគោលការណ៍ទូទៅនៃច្បាប់ ដែលបទប្បញ្ញត្តិ និតិប្រតិបត្តឬប្បញ្ញត្តិទាំងឡាយនៃនីតិប្រតិបត្តមិនធាក់ថយទេ ដូច្នេះអង្គប្រជុំបានឯកភាពទុកជូនសម្តេចនាយករដ្ឋមន្ត្រីជាអ្នកសម្រេច។

មាត្រា១០

- បន្ទាត់ទី២ លុបពាក្យ "**មាត្រា៥**" ជំនួសដោយពាក្យ "**ស្មារតី**" នៅចន្លោះពាក្យ "**ស្របតាម**" និងពាក្យ "**នៃ**" ។

មាត្រា១២

- បន្ថែម "**រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី(១រូប)សមាជិក**" ទៅក្នុងសមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងអាងទន្លេថ្នាក់ជាតិ។

មាត្រា១៣

- រាល់ពាក្យ "**សម្រាប់គ្រប់គ្រង**" សម្រួលទៅជា "**សម្រាប់ការគ្រប់គ្រង**" និងសម្រួលឃ្លាដដែលនេះនៅត្រង់មាត្រាដែលមានប្រើឃ្លានេះ។

មាត្រា១៦

- ចំណុច ក ត្រង់ទី១៤និងចំណុច ខ ត្រង់ទី១៦ ប្តូរពាក្យ "**ប្រធានខណ្ឌរដ្ឋបាលព្រៃឈើ**" ទៅជា "**នាយខណ្ឌរដ្ឋបាលព្រៃឈើ**" ។

- ចំណុច ក ត្រង់ទី១៥និងចំណុច ខ ត្រង់ទី១៥ ប្តូរពាក្យ "**ប្រធានខណ្ឌរដ្ឋបាលជលផល**" ទៅជា "**នាយខណ្ឌរដ្ឋបាលជលផល**" ។

២- សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា (សង្ខេបយោបល់ និងធាតុចូលលើចំណុចសំខាន់ៗ នៃសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ)៖

អង្គប្រជុំបានឯកភាពលើទម្រង់ ខ្លឹមសារនៃសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា (សង្ខេបយោបល់ និងធាតុចូលលើចំណុចសំខាន់ៗ នៃសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ) ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សានេះនៅវេលាម៉ោង ១៨:២៥នាទី ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែមីនា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនា ឆ្នាំ២០១៥សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,១%ធៀបនឹងខែមុននិងកើនឡើង១,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ម្ហូបអាហារ: | +៤,២% | បន្លែ: | +៨,៨% |
| ភោជនីយដ្ឋាន: | +៣,៣% | ត្រីស្រស់: | +៦,៣% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,១% | សាច់ជ្រូក: | +៥,៦% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៧% | ផ្លែឈើ: | +៤,៣% |
| ការកំសាន្ត និងវប្បធម៌: | +២,៥% | សាច់គោ: | +២,៩% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា P | ឧសភា P | មិថុនា P | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,៥% | ១,៦% | | | | | | | |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,៥% | ០,៦% | | | | | | | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |

P: តួលេខខែមេសាឧសភា និងមិថុនាឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មីនា២០១៥ | កុម្ភៈ២០១៥ | មីនា២០១៤ | *ប្រភេទ* | មីនា២០១៥ | កុម្ភៈ២០១៥ | មីនា២០១៤ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០១០៛/១$ | ៤០២៧៛/១$ | ៤០១៥៛/១$ | **បាត/ដុល្លារ** | ៣២,៥៤បាត/១$ | ៣២,៣៧បាត/១$ | ៣២,៥០បាត/១$ |
| **៛/បាត** | ១២៣៛/១បាត | ១២៤៛/១បាត | ១២៤៛/១បាត | **ដុង/ដុល្លារ** | ២១៥១៥ដុង/១$ | ២១៣៣៥ដុង/១$ | ២១០៨៥ដុង/១$ |
| **៛/ដុង** | ០,១៨៦៛/១ដុង | ០,១៨៩៛/១ដុង | ០,១៩០៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមីនាឆ្នាំ២០១៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១១៧៩,៧ពាន់លានរៀល( *មធ្យមប្រចាំខែ ៩២% នៃផែនការ*) ក្នុងនោះ ចំណូលចរន្តចំនួន១១៧០,៥ពាន់លានរៀល( *មធ្យមប្រចាំខែ ៩០% នៃផែនការ*) និងចំណូលមូលធនមាន៩,១ពាន់លានរៀល( តាមតួលេខ ធនាគារជាតិ )។

- ➢បើធៀបនឹងខែមុនចំណូលថវិកាជាតិកើនឡើង៦៤,៨% និងកើនឡើង៤៤,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:
  - ✓ចំណូលសារពើពន្ធមានចំនួន១០៣២,៨ ពាន់លានរៀល កើនឡើង៥០,៣%ធៀបនឹងខែមុន និងកើនឡើង៤៣,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ ធនាគារជាតិ )។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣–២០១៥ (ពាន់លានរៀល)




  - ✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១៣៧,៧ពាន់លានរៀល កើនឡើង៣៨៧,៦% ធៀបនឹងខែមុននិង កើនឡើង៤២,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន( តាមតួលេខ ធនាគារជាតិ )។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:+១៣,៧% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១៧,៧%) | ➢ នេសាទ:-៥,៣% | (-៣៤,៣%) |
| | | ➢រុក្ខាប្រមាញ់: | ( ) |
| ➢ ចំណូលពន្ធដារ: +៩៥,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+៨៤,៤%) | ➢សម្បទានរ៉ែ:+២២៦,៦% | (-៤០,៦%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៨៧,៧% | (-៣៥,២%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:+៣៣,២% (តាមតួលេខ រតនាគារជាតិ) | (-៣,៦%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: +១០០១៥១៤,៨% | (-២,៦%) |
| ✧ កាស៊ីណូ :+២១,៧% | (-៤,៧%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -១១,៩% | (-៦,៧%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +១៤១,១% | (-៧៤,៣%) | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +២៤៦៩,៨% | (+១២៧,៥%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៣៨,៩% | (+២៣,៨%) | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ: | |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៦៤៨,៨ពាន់លានរៀល(*មធ្យមប្រចាំខែ ៣៨% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៥៦០,៥ ពាន់លានរៀល (*មធ្យមប្រចាំខែ ៥០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៨៨,៣ពាន់លានរៀល(តាមតួលេខ រតនាគារជាតិ)។

**ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥**

➢ចំណាយថវិកាជាតិកើនឡើង៣១,៧%ធៀបនឹងខែមុនប៉ុន្តែថយចុះ៨,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ៤៦,៦% ធៀបនឹងខែមុន ប៉ុន្តែថយចុះ២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។




**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន **៥៣០,៩**ពាន់លានរៀល (តាមតួលេខ រតនាគារជាតិ)។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនាឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម៖ មិនទាន់មានតួលេខ

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៥

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៩% | ១៨% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៦% | ១៣,៧% | | | | | | | | | | |

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | មីនា២០១៥ | កុម្ភៈ២០១៥ | មីនា២០១៤ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល)<br>ក្នុងនោះ ជារៀល | ៤០៤១៦ | ៣៩០១៨ | ៣១៥៤៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | | ៨៨១៥ | ៦០៤៣ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | | ៥,៨៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | | ១៥,៩៦% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | | ៤,២៧% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | | ១១,១៨% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងខែមីនាឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៨ពាន់តោន ថយចុះ១៥%ធៀបនឹងខែមុន និងថយចុះ៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤៧៩,៩GWHមានការកើនឡើង១៩%ធៀបនឹងខែមុន និងកើនឡើង៣០%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន ៤៥,២ GWHមានការថយចុះ៣២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៨៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៤៩៥,២លានដុល្លារមានការកើនឡើង៤%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –មិនា២០១៥ | ចំនួន–កុម្ភៈ២០១៥ | ចំនួន–មិនា២០១៤ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២១ | ៩ | ២៣ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៣៣៦ | ១៣១៥ | ១១៣៦ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | | — | ១៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | — | |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១០៨១,៥ពាន់ម$^{២}$កើនឡើង៤៦៤%ធៀបនឹងខែមុននិងកើនឡើង១០១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៣៤៩,២លានដុល្លារកើនឡើង៥៦២%ធៀបនឹងខែមុននិងកើនឡើង៨៤%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² —មិនា២០១៥ | ពាន់ម² —កុម្ភៈ២០១៥ | ពាន់ម² —មិនា២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៩១០,៤ | ៤៩,៧ | ៤១៦,១ |
| ▪ ឧស្សាហកម្ម | ១២១ | ១២៥,៧ | ៣០,៧,៧ |
| ▪ទេសចរណ៍ | ៨,៧ | ៦,៧ | ៣៣,៩ |
| ▪ពាណិជ្ជកម្ម | ២៧,៩ | ៣,២ | ៣០,៤ |
| ▪ផ្សេងៗ | ៥ | ៣,១ | ២៦,៤ |
| អនុញ្ញាតសរុប | ១០៨១,៥ | ១៩២ | ៥៣៨,៧ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន ៨៤% និងឧស្សាហកម្ម១១%នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—មិនា២០១៥ | នាក់—កុម្ភៈ២០១៥ | នាក់—មិនា២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ ( ទីភ្នាក់ងារជាតិមុខរបរ និងការងារ ) | ៧៣៥ | ១០២២ | ៣៤០ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១០០២៣ | ២៩៨៨ | ៣០៤១ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩១៨៦ | ១៥៧៤ | ២៥៣១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៨៣៧ | ១៤១៤ | ១១៥៣ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មិនា២០១៥ | កុម្ភៈ២០១៥ | មិនា២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៨២៥,៣ | ៣៥,៧ | ២២១,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៧៨,២ | ០,០ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៧៨,៧ (២៥,២) | ៣៥,៧ (៨,៩) | ៨៦,១ (៧) |
| វិស័យទេសចរណ៍ | ២៧,២ | ០,០ | ៨៥,៣ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២៤៤១,២ | ០,០ | ៥០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៨ | ១២ | ១៣ |
| បង្កើតការងារ (ពាន់នាក់) | ៣១,៨ | ១៣,៤ | ១៤,៦ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —មិនា២០១៥ | ចំនួន—កុម្ភៈ២០១៥ | ចំនួន—មិនា២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣២៧ | ៣៥៥ | ៣៥៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២ | ៥ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | | ៤៣៣ |

➢ **ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៨៤៤,៥ពាន់តោនកើនឡើង១១%ធៀបនឹងខែមុន និង កើនឡើង១០%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៨% | (+២២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-២៦% | (-៦៥%) |
| ▪ កំពង់ផែកំពង់សោម:+១៧% | (+៤១%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៦៤% | (-៣%) |

➢ **ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៨,២ | -២០% | +៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤០,៤ | -១១% | +៦៩% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥១២,៩ | -៥% | +៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមីនាមានចំនួន ៣៩៦៥,៨ពាន់លានរៀល (ស្មើនឹង ៩៩១,៥លានដុល្លារ ស.រ.អា.)ថយចុះ៣,១%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣០,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១០,៥% | +២១,៥% | រថយន្តសរុប (ព.ល.រ) | +២៦,៥% | +២៣,៣% |
| ប្រេងម៉ាស៊ូត | +១០% | +៤,៥% | រថយន្តសរុប (គ្រឿង) | +៤៧,៦% | +១២,៤% |
| ឧស្ម័ន | -៣០% | +៣៨,៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៧,១% | +២,៧% |
| អគ្គិសនីនាំចូល | +១៥,៥% | -២៥% | ម៉ូតូ (គ្រឿង) | +៨,២% | +១៦,៦% |
| ដែកសំណង់ | +៥៩,៦% | -១១,១% | អង្ករ | +៦១,៥% | +២៦,១% |
| ស៊ីម៉ង់ត៍ | -៤,៣% | -១៩,៤% | ផ្លែឈើនិងបន្លែ | -១៤,៤% | -៤៩% |
| គ្រឿងអេឡិចត្រូនិក | -៤,៧% | -១២,៩% | ជីនិងថ្នាំកសិកម្ម | +១៣,២% | -៥៤,៦% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១៥,៤% | -៥,៤% |

➡ **ការនាំចេញ** ខែមីនាឆ្នាំ២០១៥ មានចំនួន**២៦៨៧**ពាន់លានរៀល ស្មើនឹង**៦៧១,៧**លានដុល្លារ ស.រ.អា. (**៦៧,៩**% នៃការនាំចូល)កើនឡើង២% ធៀបនឹងខែមុននិងកើនឡើង២,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៣៥៦,៦% | -៧៦,១% | ផលិតផលនេសាទ | -៨៥,៣% | -៨៨,១% |
| វាយនភណ្ឌនិងស្បែកជើង | -៧,១% | -៤% | កៅស៊ូ | +៥៣,២% | +១៦៦,២% |
| អង្ករ | +៩៦,៤% | +១២៥,៨% | | | |

➡ក្នុងខែមីនានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១២៧៨,៩ពាន់លានរៀល ស្មើនឹង ៣១៩,៧ លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនាឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណាយថវិកាជាតិ<br>ចំណាយចរន្ត | +៣១,៧%<br>+៤៦,៦% | -៨,៨%<br>-២,៣% | បើធៀបពាខែដើមឆ្នាំ២០១៥ និង២០១៤ ចំណាយថវិកាជាតិថយចុះ ២% ស្មើនឹង ៣៧ពាន់លានរៀល។ រីឯចំណាយចរន្តថយចុះ៧% ស្មើនឹង១០៦ពាន់លានរៀល។ |
| ២ | ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើង | -៧,១% | -៤,0% | — |

## ៧) សេចក្ដីសន្និដ្ឋាន

បញ្ហាគួរឲ្យចាប់អារម្មណ៍ពីកិច្ចពិភាក្សារបស់អង្គប្រជុំនាខែនេះគឺ សារធាតុគីមីពុលក្នុងម្ហូបអាហារ (Food contamination) ដែលត្រូវបានប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃដោយប្រជាពលរដ្ឋកម្ពុជា និងផលវិបាកចេញពីសកម្មភាពនេះ។

ម្ហូបអាហារដែលផ្ទុកសារធាតុគីមីពុលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពអ្នកប្រើប្រាស់ ប៉ុន្តែយើងមិនអាចដឹងភ្លាមៗទេ លុះត្រាតែប៉ុន្មានឆ្នាំបន្ទាប់ពីការរងឥទ្ធិពលជាប្រចាំ (ឧទាហរណ៍ ដូចជាជំងឺមហារីក ជំងឺទឹកនោមផ្អែម ការចុះខ្សោយសរីរាង្គខាងក្នុងដូចជាថ្លើម ប្រមាត់ តម្រងនោមជាដើម)។ គេមិនអាចកាត់បន្ថយឬបំបាត់សារធាតុគីមីក្នុងម្ហូបអាហារតាមរយៈការចំអិនឡើយ។ សព្វថ្ងៃនេះប្រជាពលរដ្ឋកម្ពុជា រងគ្រោះពីសារធាតុគីមីក្នុងម្ហូបអាហារដែលមានប្រភពចម្រុងៗដូចជា៖

១. សារធាតុគីមីកសិផល (Agrochemicals) ដែលប្រើប្រាស់ក្នុងការដាំដុះ ការចិញ្ចឹមសត្វក្នុងគោលបំណងបង្កើនទិន្នផល កាត់បន្ថយរយៈពេលដាំដុះ ឬ ចិញ្ចឹម និងថ្លៃដើម។



២. ថ្នាំសម្លាប់សត្វល្អិត (Pesticides and carcinogens)

៣. សារធាតុគីមីជំនួយ (Chemical supplements) ដែលប្រើដើម្បីរក្សាគុណភាព សម្រស់និងរសជាតិ ផលិតផលដូចជាសសៃគុយទាវ សាច់ បន្លែផ្លែឈើ កាហ្វេ។ល។

បច្ចុប្បន្នម្ហូបអាហារយ៉ាងច្រើនត្រូវបាននាំចូលពីប្រទេសជិតខាង: សត្វ សាច់សត្វ បន្លែ ផ្លែឈើ និងម្ហូបអាហារកែច្នៃ ដែលមានការផ្ទុកសារធាតុគីមី ក្នុងគោលបំណងរក្សាគុណភាព សម្រស់ កាត់បន្ថយថ្លៃដើម និងស្វែងរកប្រាក់ចំណេញខ្ពស់។តាមតួលេខដែលកត់ត្រាបាន កម្ពុជានាំចូលបន្លែនិងផ្លែឈើប្រហែល ២០០តោនក្នុង១ថ្ងៃពីប្រទេសជិតខាង។

ការផ្ទុកសារធាតុគីមីពុលក្នុងម្ហូបអាហារជាបញ្ហាធ្ងន់ធ្ងរសម្រាប់សង្គមជាតិទាំងមូល ដូច្នេះសុវត្ថិភាពចំណីអាហារត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់។ ការអនុវត្តបញ្ញត្តនានាត្រូវតែមានការរិតបន្តឹងចំពោះការប្រើប្រាស់សារធាតុគីមីក្នុងម្ហូបអាហារ ជាពិសេសលើទំនិញនាំចូល។

កាំកុងត្រូល និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករមានសិទ្ធអំណាចរិតបន្តឹង ឬហាមឃាត់ការនាំចូលម្ហូបអាហារដែលផ្ទុកសារធាតុគីមីគ្រោះថ្នាក់ដល់សុខភាព (ថ្នាំសម្លាប់សត្វល្អិត សារធាតុគីមីជំនួយជាដើម) ។ ដើម្បីការពារសុខភាពជូនប្រជាពលរដ្ឋ គួររាជរដ្ឋាភិបាលចំណាយថវិកាមួយចំនួនបង្កើតមន្ទីរពិសោធដែលមានសមត្ថភាពត្រួតពិនិត្យកាកសំណល់ ថ្នាំពុលនៅក្នុងបន្លែ ផ្លែឈើ និងម្ហូបអាហារនានា។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៤/១៥ ម៉ោង០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំផ្ទៃក្នុងថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៤/១៥ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិនិត្យលើប្លង់ពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/០៤/១៥ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA និងតំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៦/០៤/១៥ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការស្ពានត្សឹបាសា ប្រវែង ២.២១៥ម៉ែត្រ និងផ្លូវតភ្ជាប់ក្បាលស្ពាន ប្រវែង ៣.១០០ម៉ែត្រ ក្រោមគម្រោងជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងឯកឧត្តម **អាគីហ៊ីរ៉ូ នីស៊ីមូរ៉ា អនុរដ្ឋមន្ត្រី** ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទេសចរណ៍ នៃប្រទេសជប៉ុន នៅស្រុកលើកដែក ខេត្តកណ្តាល។ |
| ៥ | ០៦/០៤/១៥ ម៉ោង១៥:៥០នាទី | អញ្ជើញទៅខេត្តសៀមរាប ដើម្បីត្រួតពិនិត្យលើការងារសាងសង់ពង្រីកបន្ថែមនូវអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប។ |
| ៦ | ០៧/០៤/១៥ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីត្រួតពិនិត្យលើការងារសាងសង់ពង្រីកបន្ថែមនូវអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប នៅខេត្តសៀមរាប។ |
| ៧ | ០៧/០៤/១៥ ម៉ោង១២:១៥នាទី | អញ្ជើញត្រឡប់ពីខេត្តសៀមរាប ដែលបានត្រួតពិនិត្យលើការងារសាងសង់ពង្រីកបន្ថែមនូវអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប។ |
| ៨ | ០៨/០៤/១៥ ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤-២០១៥ និងទិសដៅការងារឆ្នាំ២០១៥-២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៩ | ០៩/០៤/១៥ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសូត្រមន្ត រាប់បាត្រ អបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ គ.ស ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ០៩/០៤/១៥ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ពានរង្វាន់ជ័យលាភីកីឡាប៉េតង់ ជើងឯកពិភពលោក និងកីឡាផ្សេងទៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១១/០៤/១៥ ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំពិភាក្សាអំពីដំណើរការសហគមន៍កសិកម្មស្រុកគីរីវង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅស្រុកគីរីវង់ ខេត្តតាកែវ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | **១៩/០៤/១៥<br>ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយប្រធាន អនុប្រធានសាខាបក្ស សហជីពកម្មករ និយោជិត និងតំណាងមន្ត្រីរាជការ គ្រូបង្រៀន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៣ | **២១/០៤/១៥<br>ម៉ោង០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឌួត លុច** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២១/០៤/១៥<br>ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ។<br>២-សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា (សង្ខេបយោបល់ និងធាតុចូលលើចំណុចសំខាន់ៗ នៃសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ)។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២២/០៤/១៥<br>ម៉ោង១៧:១៥នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោក TRABETON និងលោក MENANTEAU ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៣/០៤/១៥<br>ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៤/០៤/១៥<br>ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីផ្ទេរតំណែងថ្នាក់ដឹកនាំអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ នៃប្រាសាទព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៨/០៤/១៥<br>ម៉ោង១៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងស្វាគមន៍ ជូនគណៈប្រតិភូរបស់អង្គការ ICAPP លើកទី២ ស្តីពី "ការជួញដូរមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខា ភ្នំពេញ។ |
| ១៩ | **២៩/០៤/១៥<br>ម៉ោង១០:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសិក្ខាសិលា ជូនគណៈប្រតិភូរបស់អង្គការ ICAPP លើកទី២ ស្តីពី "ការជួញដូរមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខា ភ្នំពេញ។ |
| ២០ | **៣០/០៤/១៥<br>ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | **៣០/០៤/១៥<br>ម៉ោង១២:០០នាទី<br>ដល់១៣:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in